# مدرسة اهل البيت

صلوات الله عليهم

# សាលា
# អាស្ហ់លុល-បៃត៍

## សៀវភៅ អាក់ខ្ឡាក់ ( أَخْلَاقٌ សីលធម៌)

## ថ្នាក់ទី ៣ (អាយុ ៧-៨ ឆ្នាំ)

قَالَ اَلنَّبِيُّ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ : طَلَبُ اَلْعِلْمِ فَرِيضَةٌ عَلَى كُلِّ مُسْلِمٍ وَ مُسْلِمَةٍ (بحار الأنوار ج ١ ص ١٧٧)

ព្រះសាស្ដាﷺមានព្រះវចនៈថា៖ "ស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចលើមុស្លីមប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ ទុកចិត្តលើអល់ឡោះហ្ ﷻ ..................... ៥
មេរៀនទី ២ របៀបចូលបង្គន់ ..................... ៧
មេរៀនទី ៣ របៀបបរិភោគ ..................... ១០
មេរៀនទី ៤ ខិតខំធ្វើការ ..................... ១៣
មេរៀនទី ៥ និយាយត្រង់/និយាយកុហក ..................... ១៦
មេរៀនទី ៦ ថែរក្សាទ្រព្យរបស់អ្នកដទៃ (أَمَانَة) ..................... ១៩
មេរៀនទី ៧ អ្នកនឹងទទួលបានតាមកម្មផល ..................... ២២
មេរៀនទី ៨ ត្រូវផ្តាប់ព្រះហឫទ័យអល់ឡោះហ្ តែម្យ៉ាង ..................... ២៥
មេរៀនទី ៩ ការស្អាត ..................... ២៨
មេរៀនទី ១០ គោរពឪពុកម្តាយ ..................... ៣១
មេរៀនទី ១១ គោរពគ្រូ ..................... ៣៥
មេរៀនទី ១២ ធ្វើឲ្យគេតូចចិត្ត ..................... ៣៨
មេរៀនទី ១៣ បាបតូចនិងបាបធំ ..................... ៤១
មេរៀនទី ១៤ របៀបចូលក្នុងផ្ទះ ..................... ៤៤
មេរៀនទី ១៥ របៀបចេញពីផ្ទះ ..................... ៤៦
មេរៀនទី ១៦ កំហឹង ..................... ៤៨
មេរៀនទី ១៧ អ៊ីសរ៉ហ្វ (إِسْراف ការខ្ជះខ្ជាយ) ..................... ៥១

## មេរៀនទី ១

# ទុកចិត្តលើអល់ឡោះហ៍ﷻ

អល់ឡោះហ៍ﷻស្រឡាញ់មនុស្សស្លូតត្រង់ ។ ព្រះអង្គﷻថែរក្សាមនុស្សស្លូតត្រង់ទាំងអស់ ។

កាលព្រះសាស្តាមូសា﵇ប្រសូត មាតាព្រះអង្គ﵇ខ្លាចរេហ៍ពលរបស់ហ្វៀរអោ៊ន៍សម្លាប់ព្រះអង្គ﵇ ។ គាត់ក៏បានទៅរកជាងឈើឈ្មោះ ហ្វាស្ស៊ីល សូមឲ្យគាត់ធ្វើប្រអប់ឈើមួយ ។

ហ្វាស្ស៊ីលចង់ដឹងថាតើគាត់ចង់យកប្រអប់ទៅធ្វើអ្វី ។ ព្រោះតែមាតារបស់ព្រះសាស្តាមូសា﵇ជាមនុស្សស្លូតត្រង់បានជាគាត់ប្រាប់ការពិត ពោលគឺ គាត់ចង់លាក់កូនប្រុសគាត់នៅក្នុងប្រអប់នោះ ។

ហ្វាស្ស៊ីលក៏បានធ្វើប្រអប់នោះ តែព្រោះតែគាត់ជាបក្សពួករបស់ហ្វៀរអោ៊ន៍ បានជាគាត់ទៅប្រាប់ហ្វៀរអោ៊ន៍ឲ្យដឹងផែនការណ៍ ។ តែពេលគាត់ទៅដល់វាំង គាត់លែងនិយាយរួច ទៅជាគ ។ មនុស្សក្នុងវាំងថាគាត់ឆ្កួត ដេញគាត់ចេញពីក្នុងវាំង ។

ពេលគាត់ត្រឡប់មកផ្ទះវិញ គាត់និយាយបានវិញជាធម្មតា ។ ហេតុដូច្នេះ គាត់ត្រឡប់ទៅវាំងវិញ ដើម្បីសាកល្បងម្តងទៀត ។

លើកនេះ គាត់មិនត្រឹមតែគទេ តែថែមទាំងថ្លង់ផង មិនអាចនិយាយប្រាប់គេបានទេ ។

ហ្វាស្ស៊ីលក៏បានដឹងថា ព្រះសាស្តាមូសា﵇ជាព្រះសាស្តាពិតប្រាកដមែន អល់ឡោះហ៍ﷻជួយព្រះអង្គ﵇ពីគ្រោះថ្នាក់សព្វគ្រប់ ។ ហ្វាស្ស៊ីលក៏បានទៅជាមុស្លីម ។

## លំហាត់ ១

ចូរនិយាយប្រាប់ឪពុកម្ដាយអ្នកថា ហេតុអ្វីម្ដាយព្រះសាស្ដាមូសាﷺឲ្យគេធ្វើប្រអប់ ។



តើហ្វាស៊ីលកើតអ្វី លើកដំបូង ពេលគាត់ទៅប្រាប់ហ្វៀរអ៊ូន៍រឿងព្រះសាស្ដាមូសាﷺ ?

______________________________

______________________________

តើហ្វាស៊ីលកើតអ្វី លើកទីពីរ ពេលគាត់ទៅប្រាប់ហ្វៀរអ៊ូន៍រឿងព្រះសាស្ដាមូសាﷺ ?

______________________________

______________________________

ចុងក្រោយ តើហ្វាស៊ីលដឹងអ្វី ?

______________________________

______________________________

## មេរៀនទី ២

# របៀបចូលបង្គន់

មុនចូលបង្គន់ អ្នកត្រូវពាក់ស្បែកជើង ព្រោះកន្លែងដើរអាចទទឹក (ចម្លងណាយ៉ីស) ជើងអ្នកនឹងទទឹកដែរ (ទៅជាណាយ៉ីសដែរ) ។

ពេលអ្នកទៅបង្គន់ ចូរឈានជើងឆ្វេងចូលមុនជើងស្តាំ ។

យកទឹកដោយបោយឬធុង មុនអង្គុយ ។



បើអ្នកចូលបង្គន់នៅឯសាលារៀន ឬកន្លែងផ្សេងដែលមិនមានទឹកសម្រាប់លាងទេ អ្នកត្រូវជូតដោយក្រដាសក្រោយពីបានបត់ជើងរួច ។

នៅឯកន្លែងទាំងនេះ អ្នកត្រូវមានកូនដបមួយជាប់តាមខ្លួនសម្រាប់ដាក់ទឹកពេលត្រូវការ ។

បើអ្នកបានប្រើក្រដាសជូត អ្នកត្រូវប្រាប់ម្តាយថាអ្នកមិនបានប្រើទឹកទេ ដើម្បីនឹងឲ្យគាត់ដឹងថាខោទ្រនាប់អ្នកណាយ៉ីស ហើយត្រូវបោកខោទ្រនាប់នោះ ។

ពេលអ្នកចូលបង្គន់ អ្នកត្រូវអង្គុយលើបង្គន់ ។ អល់ឡោះហ៊្ វَجَلَّ عَزَّ មិនសព្វព្រះហឫទ័យទេដែលអ្នកបត់ជើងតូចឈរនោះ ។





ពេលអ្នកបត់ជើងរួច ចូរលាង ២ ដង យកល្អឲ្យ លាង ៣ ដង បើអ្នកមានទឹកគ្រប់គ្រាន់ ។



រួចហើយងើបឡើង ស្លៀកពាក់វិញ ហើយចូរទាញខ្សែ ឬ សង្កត់ប្រដាប់ចាក់ទឹកបង្គន់ ។





រួចហើយចូរលាងដៃទាំងពីរហើយជូតឲ្យស្ងួត ។



ចេញពីបង្គន់ដោយឈានជើងស្តាំមុនជើងឆ្វេង ។



ចូរចងចាំថា អ្នកមិនត្រូវអង្គុយបែរមុខទៅរកគិ្ឞបឡាត់ ឬបែរខ្នងដាក់គិ្ឞបឡាត់ទេ ។ បើបង្គន់បែរមុខទៅរកគិ្ឞបឡាត់ ចូរអ្នកអង្គុយបញ្ឆិតពីគិ្ឞបឡាត់បន្តិច ។






ចូរចងចាំថាអ្នកមិនត្រូវនិយាយនៅក្នុងបង្គន់ទេ ។

## លំហាត់ ២

# របៀបចូលបង្គន់

ចូរដាក់លេខរៀងលើរូបភាពឲ្យត្រូវតាមលំដាប់ ។











**មេរៀនទី ៣**

# របៀបបរិភោគ

អល់ឡោះហ៊្ជ មានព្រះបន្ទូលនៅក្នុងគួរអាន ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ អាយ៉ាស់ ១៧២ ថា៖ *"បណ្ដាអ្នកមានសទ្ធាអើយ ចូរពួកអ្នកបរិភោគវត្ថុបរិសុទ្ធដែលយើងបានផ្ដត់ផ្គង់ពួកអ្នក ចូរពួកអ្នកអរព្រះគុណអល់ឡោះហ៊្វ ។" (២:១៧២)*

មុនអ្នកអង្គុយបរិភោគ ចូរអ្នកដឹងច្បាស់លាស់ថាចំណីដែលអ្នកនឹងបរិភោគនោះជាចំណីដែលច្បាប់អនុញ្ញាត ពោលគឺ ជាចំណីហាឡាល់ ។



ចូរកុំបរិភោគនៅកន្លែងណាដែលមានស្រា ។

ចូរកុំបរិភោគ ទាល់តែមិនអាចធ្វើការគោរពសក្ការៈអល់ឡោះហ៊្វ បានឡើយ ។ មូលហេតុមួយគត់ដែលអ្នកបរិភោគនោះគឺដើម្បីមានកម្លាំងធ្វើការគោរពសក្ការៈអល់ឡោះហ៊្វ ។




ចូរកុំបរិភោគឲ្យពេញពោះ ។ អ្នកត្រូវឈប់បរិភោគមុនពោះពេញ ។



មុនបរិភោគ អ្នកត្រូវលាងដៃ ។ យកល្អកុំជូតឲ្យស្ងួត ។

ចូរអង្គុយចាំគេចូលមកអង្គុយគ្រប់គ្នាសិន ។



មុនចាប់ផ្ដើមបរិភោគ ចូរសូត្រថា بِسْمِ اللهِ الرَّحْمٰنِ الرَّحِيم ហើយចូរលិទ្ធអំបិលបន្តិច ។





ចូរបរិភោគម៉ាត់តូចៗដោយប្រើដៃស្តាំ (កុំបរិភោគពេញមាត់តែម្តង) ចូរទំពាអាហារឲ្យល្អិតដោយបិទមាត់មុនលេប ។



បើអាហារក្តៅពេក ចូរកុំផ្លុំ ។ ចាំវាឲ្យត្រជាក់ដោយខ្លួនឯង ។



ចូរកុំនិយាយពេលបាយពេញមាត់ ចូរកុំមើលគេបរិភោគ ។

ចូរកុំក្រោកចេញពីកន្លែងបើមិនទាន់អស់បាយពីចានទេ (មុនបរិភោគ ចូរដួសយកអាហារត្រឹមតែអាចបរិភោគអស់) ។

មុនក្រោកចេញពីកន្លែង ចូរលិទ្ធអំបិលបន្តិចទៀត ហើយថា اَلْحَمْدُ لِلّٰهِ ។

ចូរខ្ពុរមាត់ លាងដៃហើយជូតឲ្យស្ងួត ។





# លំហាត់ ៣

ចូរបំពេញឃ្លាខាងក្រោមនេះដោយពឹងផ្អែកលើរូបភាពខាងក្រោម ។

១) មុនបរិភោគ អ្នកត្រូវ_______ដៃ ។
២) អ្នកមិនត្រូវអង្គុយកន្លែងណាដែលមាន_______ ។
៣) អ្នកត្រូវអង្គុយចាំគេចូលមកអង្គុយអស់សិនមុននឹង_______ ។
៤) មុនបរិភោគអ្នកត្រូវលិទ្ធ_______ ។
៥) អ្នកត្រូវរង់ចាំឲ្យ_____________ត្រជាក់សិន ។
៦) អ្នកមិនត្រូវបរិភោគ_______ច្រើនពេកទេ ។
៧) ពេលអ្នកបរិភោគរួច អ្នកត្រូវ_______ ហើយ_______ដៃ ។ ។





ដៃស្តាំ


ជូតដៃ


លាងដៃ


ស្រា


ចាំឲ្យត្រជាក់


មើលគេបរិភោគ



បរិភោគពេញពោះ

**មេរៀនទី ៤**

# ខិតខំធ្វើការ

អល់ឡោះហ្ ﷻ មានព្រះបន្ទូលនៅក្នុងគួរអាន ស៊ូរ៉ោះត៍ អាល់-ណាជ្ម៍ អាយ៉ាស់ ៣៩ ថា៖ *"មនុស្សនឹងមិនបានអ្វីក្រៅពី[លទ្ធផលនៃ]ការខំប្រឹងប្រែងរបស់ខ្លួនទេ ។" (៥៣:៣៩)*

យើងមិនអាចបានចម្រើនទេ បើយើងមិនខិតខំប្រកបកិច្ចការទេនោះ ។

អ្នកធ្វើស្រែចម្ការ សាបព្រោះគ្រាប់ពូជ ស្រោចទឹក នឹងបានទទួលផល ។

យើងគប្បីយកគំរូតាមជីវិតរស់នៅរបស់ព្រះសាស្ដា ﷺ យើង ដើម្បីនឹងយល់ដឹងថាខិតខំប្រកបកិច្ចការមានសារៈសំខាន់សម្រាប់យើងរាល់គ្នា មិនត្រូវពឹងផ្អែកលើអ្នកដទៃទេ ។

ថ្ងៃមួយព្រះសាស្ដា ﷺ បានធ្វើដំណើរជាមួយមិត្តព្រះអង្គ ﷺ ។ ទាំងអស់គ្នាបានឈប់នៅកន្លែងនីមួយដើម្បីបរិភោគនិងសម្រាក ។ គេគិតនឹងសំឡេះពពែមួយដើម្បីអាំង ។

ម្នាក់ថា៖ "ខ្ញុំជាអ្នកសំឡេះពពែ ។" ម្នាក់ទៀតថា៖ "ខ្ញុំជាអ្នកពន្លាត់ស្បែកវា ។" អ្នកទីបីថា៖ "ខ្ញុំជាអ្នកអាំងវា ។"

ម្នាក់ៗកាន់មុខការមួយដោយស្ម័គ្រចិត្ត ។

ព្រះសាស្ដា ﷺ មានព្រះវចនៈថា៖ "ខ្ញុំ ﷺ ជាអ្នករកឧសនៅក្នុងព្រៃមកដុតពពែ ។"

បណ្ដាសាវកព្រះអង្គ ﷺ បានទូលថា៖ "ព្រះសាស្ដា ﷺ អឺយ ព្រះអង្គ ﷺ មិនបាច់ធ្វើអ្វីទេ ។ អស់ទូលបង្គំនឹងធ្វើការទាំងអស់ ។"

ព្រះសាស្ដា ﷺ បានតបថា៖ "ខ្ញុំ ﷺ ដឹងថាអស់លោកអាចធ្វើការទាំងអស់បាន ។ តែខ្ញុំ ﷺ មិនចង់ឲ្យអស់លោកខ្លាចក្រែងចិត្តខ្ញុំ ﷺ ទេ ។" ព្រះសាស្ដា ﷺ ក៏បានទៅដើររកឧសក្នុងព្រៃ ។

សាសនាអ៊ីស្លាមចាត់ទុកការប្រកបការងារជាកាតព្វកិច្ច ។

# លំហាត់ ៤

ចូរនិយាយប្រាប់ឪពុកម្ដាយអ្នករឿងព្រះសាស្ដាﷺធ្វើការ ។

# មេរៀនទី ៥

# និយាយត្រង់/និយាយកុហក

សេចក្ដីទៀងត្រង់គឺសេចក្ដីស្មោះ - ស្មោះទាំងពាក្យសម្ដី ស្មោះទាំងទង្វើ ។

និយាយកុហកផ្ទុយពីនិយាយត្រង់ ។

អល់ឡោះហ្ទ៍ﷻហាមយើងនិយាយកុហក វាជាប្រការហ៊ារ៉ាំ ។ ទោះជានិយាយកុហកតិចក្ដី ច្រើនក្ដី និយាយកុហកមែនទែនឬនិយាយកុហកលេងក្ដី វានៅតែជាប្រការហ៊ារ៉ាំ ។

គំរូនៃសេចក្ដីទៀងត្រង់ដ៏ប្រសើរបំផុត គឺព្រះសាស្ដាមូហ៊ាំម៉ាដ់ﷺរបស់យើង ដែលគេស្គាល់ច្បាស់ថាជាសច្ចការី (ឬហៅជាសាមញ្ញថាអ្នកសច្ចៈ) ទោះបីពួកសត្រូវរបស់ព្រះអង្គﷺក៏ថាដូច្នេះដែរ ។



ថ្ងៃមួយ មានបុរសម្នាក់មកជួបព្រះសាស្ដាﷺ ទូលព្រះអង្គﷺថា គាត់សាងបាបច្រើនដូចជាផឹកស្រា លេងល្បែងស៊ីសង លួចគេជាដើម ថាពេលនេះគាត់បានសម្រេចចិត្តទៅជាមុស្លីម តែគាត់អាចឈប់សាងបាបបានតែម្ដងមួយទេ ។

ព្រះសាស្ដាﷺបានប្រាប់គាត់ថាឲ្យគាត់ឈប់និយាយកុហក ។

បុរសក៏ព្រមទទួលដោយគិតក្នុងចិត្តថាគាត់បានដោះសារួចខ្លួនពេលនេះ ។

ថ្ងៃស្អែក ពេលបុរសនោះចេញទៅប្រព្រឹត្តប្រការអាក្រក់ (លួចគេ) គាត់ឈប់ង៉ក់ដោយគិតក្នុងចិត្តថាបើគេចាប់គាត់បាន គាត់មិនអាចឆ្លើយបដិសេធបានទេ ព្រោះគាត់មិនអាចនិយាយកុហកបានទេ ។ ទោះបីគេចាប់គាត់មិនបានក៏ដោយ តើគាត់អាចយកមុខទៅជួបព្រះសាស្ដាﷺបានទេ និយាយប្រាប់ព្រះអង្គﷺនូវប្រការអាក្រក់ដែលគាត់បានធ្វើ គួរឲ្យខ្មាស់ណាស់ ។

ដូច្នេះ ពេលគាត់ឈប់និយាយកុហក បុរសនោះក៏ឈប់ប្រព្រឹត្តអំពើបាបឯទៀតដែរ ។

និយាយកុហកម្តងនាំឲ្យនិយាយកុហកម្តងទៀត ព្រោះអ្នកព្យាយាមបិទបាំងស្នាមដានដែលចោទមកលើខ្លួនអ្នក ។ ដូច្នេះហើយបានជាគប្បីនិយាយត្រង់តាំងពីដើម ។ ពុំនោះទេអ្នកនឹងឆាប់មានទម្លាប់និយាយកុហកដោយស្វ័យប្រវត្ត ។

អល់ឡោះហ្ទ័ﷻដឹងអ្វីៗទាំងអស់ ។ ម្យ៉ាងទៀត ទោះបីអ្នកគិតថាអ្នកឆ្លើយដោះសារួចខ្លួនបាន ពុំមានអ្នកណាដឹងក៏ដោយ ចូរអ្នកចងចាំថាអល់ឡោះហ្ទ័ﷻដឹង អ្នកនឹងវិលត្រឡប់ទៅជួបព្រះអង្គﷻវិញ ។

ដូច្នេះ គប្បីនិយាយពិតហើយទទួលទោសនៅឯលោកនេះបើអ្នកបានធ្វើអំពើអាក្រក់នីមួយ ជាជាងនិយាយកុហកហើយត្រូវធ្វើទណ្ឌកម្មនៅឯលោកមុខដែលអ្នកបាននិយាយកុហកថែមពីលើអំពើអាក្រក់ដែលអ្នកបានធ្វើ ។

ដូច្នេះចូរអ្នកចងចាំថានិយាយកុហកជាអំពើហ្រាំ ទោះបីការនិយាយកុហកនោះតូចក្តី ធំក្តី ទោះបីនិយាយកុហកមែនទែនក្តីឬនិយាយកុហកលេងៗក្តី ។ ការនិយាយកុហកទាំងអស់ជាអំពើហ្រាំ ។

# លំហាត់ ៥

១) ត្រូវ ឬ ខុស ? ចូរគូសលើកន្លែងត្រូវ ។

| | ត្រូវ | ខុស |
|---|---|---|
| ១-ពេលយើងនិយាយលេង យើងមានសិទ្ធិកុហក ។ | | |
| ២-បើយើងនិយាយត្រង់ជានិច្ច យើងអាចនឹងមានបញ្ហាច្រើន ។ | | |
| ៣-ព្រោះតែគាត់បានសន្យាព្រះសាស្តាﷺ ថាគាត់នឹងលែងនិយាយកុហកទៀត បុរសដែលធ្វើអំពើបាបច្រើនអាចលះបង់ទម្លាប់អាក្រក់ទាំងអស់គាត់បានបន្តិចម្តងៗ ។ | | |
| ៤-ការនិយាយកុហកមួយនាំទៅរកការនិយាយកុហកមួយទៀត ។ | | |

២) ព្រះសាស្តាﷺយើងល្បីឈ្មោះ (ពួកសត្រូវព្រះអង្គﷺក៏ដឹងដែរ) ថាជា៖

១) សច្ចការី ។

២) បុគ្គលបរិសុទ្ធ ។

៣) បុគ្គលសុក្រឹតឥតខ្ចោះ ។

## មេរៀនទី ៦

# ថែរក្សាទ្រព្យរបស់អ្នកដទៃ (أَمَانَة)

អល់ឡោះហ៍ﷻមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ មុមីនូន អាយ៉ាស់ ៨ ថា៖ *"បណ្តាអ្នកដែលព្យាយាមរក្សាទំនុកចិត្តនិងគោរពកិច្ចសន្យារបស់ខ្លួន... ជនទាំងនេះជាបណ្តាអ្នកស្នងកេរមរតក ។" (២៣:៨-១០)*

អាយ៉ាស់ខាងលើនេះបញ្ជាក់ប្រាប់យើងថា បណ្តាអ្នកមានសទ្ធាដែលបានសម្រេចគឺបណ្តាអ្នកដែលមើលថែរក្សាទ្រព្យដែលគេផ្ញើទុកនឹងខ្លួន ដោយយកចិត្តទុកដាក់ និងបណ្តាអ្នកដែលមិនក្បត់ពាក្យសន្យា ។

គេអាចផ្ញើរបស់របរទុកនឹងអ្នកដោយចេតនាឬដោយអចេតនា ឬដោយច្រឡំ ។ គេអាចផ្ញើរបស់នីមួយនឹងអ្នកដោយសូមឲ្យអ្នកជួយមើលថែរក្សាវាជួសខ្លួនផង ឬផ្ញើវាទុកនឹងអ្នកដោយសូមឲ្យអ្នកជួយឲ្យរបស់នោះទៅមនុស្សម្នាក់ទៀត ឬអាចមានអ្នកណាម្នាក់ភ្លេចរបស់នីមួយនៅឯផ្ទះអ្នក ។

ទោះជាយ៉ាងណាក៏ដោយ អ្នកត្រូវតែមើលថែរក្សារបស់របរនោះដោយប្រយ័ត្នលុះត្រាតែរបស់នោះបានទៅដល់ដៃម្ចាស់វាវិញ ។

របស់ដែលគេផ្ញើទុកនឹងអ្នកនោះអាចតូចឬធំ ដូចកាលព្រះសាស្តាﷺបានសូមឲ្យយ៉ាបៀរផ្ញើសាឡាមទៅថៅទូតព្រះអង្គﷺ គឺអ៊ីម៉ាំ មូហាំម៉ាដ់ អាល់-បាគៀរ صلوات الله عليه والسلام ។ របស់នោះអាចមានតម្លៃឬឥតតម្លៃ ។ អ្នកត្រូវតែមើលថែរក្សារបស់នោះយ៉ាងហ្មត់ចត់ជានិច្ច ។

បើគេផ្ញើរបស់អ្វីមួយទុកនឹងអ្នក អ្នកមិនមានសិទ្ធិបើកមើលរបស់នោះទេ មិនមានសិទ្ធប្រើប្រាស់របស់នោះទេ ដោយគ្មានការអនុញ្ញាតពីម្ចាស់វា ។

កាលអ៊ីម៉ាំអាលីصلوات الله عليه والسلامបានកាន់តំណែងខ៊ិកិហ្វដឹកនាំមុស្លីម បុរសពីរនាក់ឈ្មោះត្លល់ហាស់ និង ស៊ូបៃរ៍ បានមកជួបព្រះអង្គصلوات الله عليه والسلام ។

អ៊ីម៉ាំصلوات الله عليه والسلامកំពុងតែអង្គុយបំពេញកិច្ចការរដ្ឋក្រោមពន្លឺទៀន ។ ត្លល់ហាស់និង

ស្វ៊ៃបែរអង្គុយចុះដើម្បីនិយាយជាមួយអ៊ីម៉ាំអាលីصلوات الله عليه والسلام ។ អ៊ីម៉ាំصلوات الله عليه والسلامពន្លត់ទៀន ហើយអុជទៀនមួយទៀត ។



ពេលពួកគាត់បានសួរអ៊ីម៉ាំصلوات الله عليه والسلام ថាហេតុអ្វីព្រះអង្គصلوات الله عليه والسلامពន្លត់ទៀនមួយហើយអុជមួយទៀត អ៊ីម៉ាំصلوات الله عليه والسلامបានតបថា ទៀនដំបូងត្រូវទិញដោយប្រាក់រដ្ឋព្រះអង្គصلوات الله عليه والسلامអុជវា សម្រាប់តែធ្វើកិច្ចការរដ្ឋតែម្យ៉ាងទេ ។ ព្រោះតែត្វល់ហ្ហាស្វ៊និងស្វ៊ៃបែរមកលេងអ៊ីម៉ាំصلوات الله عليه والسلام មិនមែនមកធ្វើការរដ្ឋទេនោះ បានជាព្រះអង្គصلوات الله عليه والسلامត្រូវតែអុជទៀនមួយទៀត ដែលត្រូវទិញដោយប្រាក់ផ្ទាល់ខ្លួនរបស់ព្រះអង្គصلوات الله عليه والسلام ។

ឧត្តមគតិរឿងនេះគឺ អ៊ីម៉ាំصلوات الله عليه والسلامបង្ហាញឲ្យឃើញថាទ្រព្យរបស់អ្នកដទៃមានសារៈសំខាន់ណាស់ ដល់ថ្នាក់មិនត្រូវប្រើពន្លឺទៀនដោយគ្មានការអនុញ្ញាត ។

# លំហាត់ ៦

ចូរនិយាយរឿងអ៊ីម៉ាំទី ១ របស់យើង អ៊ីម៉ាំអាលី صلوات الله عليه والسلام និងទៀន ។



ចូរសរសេរខាងក្រោមនេះ នូវអត្ថន័យដែលអ្នកដកស្រង់បានពីទង្វើរបស់អ៊ីម៉ាំអាលី صلوات الله عليه والسلام ។

**មេរៀនទី ៧**

# អ្នកនឹងទទួលបានតាមកម្មផល

អល់ឡោះហ្ម៍ﷻមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ បានី អ៊ីសរ៉អ៊ីល អាយ៉ាស់ ៨ ថា៖ *"បើពួកអ្នកធ្វើអំពើល្អ ពួកអ្នកធ្វើល្អដើម្បីខ្លួនពួកអ្នក ។ បើពួកអ្នកធ្វើអំពើអាក្រក់ វានឹងបានមកលើខ្លួនពួកអ្នក ។" (១៧:៧)*

សាវកម្នាក់របស់ព្រះសាស្តាﷺស្រឡាញ់អាយ៉ាស់នេះណាស់ ។ លោកសូត្រអាយ៉ាស់នេះឮៗជានិច្ច ។

គ្រប់ពេលដែលស្រីយ៉ាហ៊ូឌីម្នាក់បានឮអាយ៉ាស់នេះ គាត់តែងតែប្រឆាំងក្នុងបំណងធ្វើឲ្យគេឃើញថាសាសនាអ៊ីស្លាមមិនត្រឹមត្រូវទេ ។

ថ្ងៃមួយ គាត់ធ្វើបង្អែមលាយថ្នាំបំពុលផ្ញើមកលោក ។

ថ្ងៃដែលលោកទទួលបង្អែមនោះ លោកត្រូវទៅកាន់ទីក្រុង ដូច្នេះលោកបានដាក់បង្អែមនោះក្នុងហោប៉ៅហើយក៏ចេញដំណើរ ។

លោកបានជួបបុរសពីរនាក់តាមផ្លូវដែលត្រឡប់ទៅផ្ទះវិញ ក្រោយពីបានធ្វើដំណើរយូរថ្ងៃ ។ ពួកគាត់ដូចជានឿយហត់និងឃ្លានផង ។

លោកក៏នឹកឃើញបង្អែមនៅក្នុងហោប៉ៅ នឹកក្នុងចិត្តថាបុរសពីរនាក់នេះប្រហែលជាចង់បានបង្អែមនេះបរិភោគ ។ លោកក៏បានឲ្យបង្អែមស្ករនោះទៅពួកគាត់ ដោយមិនដឹងថាវាត្រូវដាក់ថ្នាំបំពុលទេ ។

បន្ទាប់ពីបានហូបស្ករនោះភ្លាម បុរសទាំងពីរនាក់សន្លប់បាត់ស្មារតី ហើយក៏ស្លាប់ ។

លុះដំណឹងមរណកម្មនេះបានឮដល់ម៉ាឌីណាស់ គេបានចាប់ខ្លួនលោកហើយនាំទៅជួបព្រះសាស្តាﷺ ។

ពេលលោកបាននិយាយរឿងរ៉ាវប្រាប់ព្រះសាស្តាﷺ ស្រីយ៉ាហ៊ូឌីដែលបានឲ្យស្ករលោកនោះត្រូវនាំខ្លួនមកជួបព្រះសាស្តាﷺដែរ ។

ពេលស្រីយ៉ាហ៊ូឌីនោះបានឃើញសាកសពទាំងពីរ គាត់សោកសៅក្រៃលែង

ព្រោះបុរសអ្នកធ្វើដំណើរទាំងពីនាក់ដែលស្លាប់នោះជាកូនរបស់គាត់ ដែលត្រឡប់មកកាន់លំនៅដ្ឋានវិញក្រោយពីបានចាកចេញទៅយូរថ្ងៃ ។

ស្រីយ៉ាហ៊្វូឌីបានសារភាពប្រាប់ព្រះសាស្តាﷺនិងសាធារណៈជន ថាគាត់មានបំណងអាក្រក់ ។

ថ្នាំបំពុលដែលគាត់បានលាយជាមួយស្ករដើម្បីសម្លាប់បុរសមុស្លីមនោះ បានផ្តាច់ជីវិតកូនប្រុសទាំងពីររបស់គាត់ ។

ឧត្តមគតិរឿងនេះគឺ គេតែងតែទទួលបាននូវអ្វីដែលខ្លួនបានសាង ។ បើអ្នកប៉ងអាក្រក់ចំពោះអ្នកដទៃ កម្មអាក្រក់អាចនឹងធ្លាក់មកលើខ្លួនអ្នក ។ ចូរអ្នកធ្វើចំពោះអ្នកដទៃនូវអំពើដែលអ្នកចង់ឲ្យគេធ្វើមកលើខ្លួនអ្នកដែរ ។

# លំហាត់ ៧

ចូរគូរនៅក្នុងបាតដៃបុរសនោះ នូវអ្វីដែលគាត់បានឲ្យទៅបុរសពីរនាក់ដែលធ្វើដំណើរត្រឡប់មកពីផ្ទះវិញ ។



តើអ្នកដកស្រង់បាននូវមេរៀនអ្វីពីរឿងនេះ ?

# មេរៀនទី ៨

## ត្រូវផ្គាប់ព្រះហឫទ័យអល់ឡោះហ៊្វតែម្យ៉ាង

អ្នកត្រូវព្យាយាមផ្គាប់ចិត្តអល់ឡោះហ៊្វﷻតែមួយគត់ជានិច្ច ។ អ្វីៗដែលអ្នកធ្វើត្រូវមានគោលដៅផ្គាប់ចិត្តអល់ឡោះហ៊្វﷻតែម្យ៉ាង ។ អ្នកមិនត្រូវស្វែងរកអ្វីផ្សេងទេក្រៅពីសំណព្វចិត្តអល់ឡោះហ៊្វﷻ ។ គ្រប់ទង្វើរបស់អ្នកត្រូវធ្វើដើម្បីសព្វព្រះហឫទ័យអល់ឡោះហ៊្វﷻ មិនមែនដើម្បីផ្គាប់ចិត្តអ្នកណាផ្សេងពីអល់ឡោះហ៊្វﷻទេ ។

ចូរចងចាំថាអ្នកនឹងវិលត្រឡប់ទៅរកអល់ឡោះហ៊្វﷻវិញ អល់ឡោះហ៊្វﷻជាអ្នកតបស្នងអ្នក ហើយចូរអ្នកជឿជាក់ប្រាកដក្នុងចិត្តថាការតបស្នងរបស់អល់ឡោះហ៊្វﷻប្រសើរជាងរង្វាន់ដែលអ្នកដទៃឲ្យអ្នក ។

កាលពីយូរអង្វែងមកហើយមានបុរសម្នាក់ប្រកបដោយញាណប្រាជ្ញា ឈ្មោះលុក្មម៉ាន ។

លោកមិនមែនសាស្តាទេ តែលោកមានប្រាជ្ញាចេះដឹងជាទីបំផុត គេគោរពលោកណាស់ ដល់ថ្នាក់គេហៅឈ្មោះស៊ូរ៉ោះគ័ត្គួរអានមួយថា លុក្មម៉ាន ។

ថ្ងៃមួយ លុក្មម៉ានប្រាប់កូនប្រុសលោកថា៖ "កូនអើយ ចូរកុំគិតតែផ្គាប់ចិត្តមនុស្ស ។ កូនមិនងាយធ្វើដូច្នេះបានទេ ។ ចូរកូនកុំយកចិត្តទុកដាក់នឹងសម្តីមនុស្ស តែចូរកូនគិតតែផ្គាប់ចិត្តអល់ឡោះហ៊្វﷻវិញ ។"



ទោះបីកូនលោកស្តាប់លោកក៏ដោយ តែលុក្មម៉ានចង់ឲ្យកូនលោកយល់មេរៀននេះ និងចងចាំជាប់ជានិច្ច ។

លុក្មម៉ានបានឲ្យកូនលោកជិះលា ចំណែកលោកវិញដើរតាមពីក្រោយ ។ កូនលោកក៏ធ្វើតាម ។

ដើរបានឆ្ងាយបន្តិចក៏បានជួបមនុស្សមួយក្រុម ។

ពេលបានឃើញកូនជិះលា ឯឪពុកចាស់ដើរតាមពីក្រោយ មនុស្សក៏បាននិយាយអំពីកូនថាពុំមានការគួរសមនិងមិនមែនជាកូនល្អទេ ព្រោះតែសុខចិត្តឲ្យឪពុកដើរឯខ្លួនឯងវិញជិះលា ។

លុក្មម៉ាននិងកូនប្រុសបានឮគេថា កូនប្រុសក៏បានចុះពីលើខ្នងលា ឪពុកឡើងជិះលា ។

ឆ្ងាយពីនោះបន្តិច ឪពុកកូនបានជួបមនុស្សមួយក្រុមទៀត ។ ពេលឃើញឪពុកជិះលា កូនប្រុសដើរតាមក្រោយ មនុស្សទាំងនោះបាននិយាយអំពីឪពុកថាមិនមែនជាឪពុកល្អទេ គិតតែខ្លួនឯង ឲ្យកូនដើរឯខ្លួនឯងជិះលា ។

លុក្មម៉ាននិងកូនប្រុសបានឮមនុស្សទាំងនោះថា លុក្មម៉ានក៏បានចុះពីលើលា ។

ឆ្ងាយពីនោះ ឪពុកកូនបានជួបមនុស្សមួយក្រុមទៀត ។ ពេលឃើញឪពុកនិងកូនដើរបណ្តើរលា ពួកមនុស្សទាំងនោះបាននិយាយអំពីអ្នកទាំងពីរថាជាមនុស្សឆោតព្រោះមិនព្រមជិះលា ។

លុក្មម៉ាននិងកូនបានឮគេថា ហើយក៏ឡើងជិះលាទាំងពីរនាក់ ។

ឆ្ងាយពីនោះបន្តិចក៏បានជួបមនុស្សមួយក្រុមទៀត ។ ពេលឃើញឪពុកនិងកូនជិះលា ពួកគេថាបុរសទាំងពីរនាក់នេះខ្វះមេត្តាដែលឲ្យសត្វតូចមួយដឹកបន្ទុកដ៏ធ្ងន់ ។

លុក្មម៉ាននិងកូនបានឮគេថា ហើយក៏ចុះពីលើលា ។

លុក្មម៉ានបែរមករកកូនហើយថា៖ "កូនបានឮនិងបានឃើញមនុស្សថាហើយឬទេ ? តើកូនយល់ហើយឬទេពេលនេះថាហេតុអ្វីកូនត្រូវគិតតែផ្គាប់ចិត្តអល់ឡោះហ៍ عز وجل ?"

ឧត្តមគតិរឿងនេះគឺ អ្នកត្រូវធ្វើអ្វីៗដើម្បីផ្គាប់ចិត្តអល់ឡោះហ៍ عز وجل មួយគត់ ។

# លំហាត់ ៨

ចូរគូររូបអ្នកដែលឡើងជិះលាជាបន្តបន្ទាប់ ពេលលុក្មម៉ានបង្ហាត់កូនឲ្យគិតតែផ្គាប់ចិត្តអល់ឡោះហ្ ﷻ តែមួយ ។









## មេរៀនទី ៩

# ការស្អាត

អល់ឡោះហ្ម៉ូﷻមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអានថា៖ *"... ព្រះអង្គសព្វព្រះហឫទ័យបណ្ដាអ្នកជម្រះបន្សុទ្ធខ្លួន..." (៩:១០៨, ២:២២២...)*

ស្អាតនិងបរិសុទ្ធមិនដូចគ្នាទេ ។

ស្អាតគឺគ្មានវត្ថុស្មោកគ្រោក គឺមានភាពស្អាត ។

បរិសុទ្ធគឺសុក្រឹតស្របច្បាប់អ៊ីស្លាម គឺមានចិត្តស្អាត ។

អ្នកត្រូវព្យាយាមឲ្យខ្លួនអ្នកស្អាតជានិច្ច និងត្រូវខិតខំប្រព្រឹត្តចិត្តកាយឲ្យបរិសុទ្ធគ្រប់ពេល ។

ហេតុអ្វីការស្អាតមានសារសំខាន់ ?

បើអ្នកមិនរក្សាការស្អាតទេ អ្នកនឹងមានជម្ងឺ ព្រោះមេរោគដែលនាំមកនូវជម្ងឺនោះនៅក្នុងវត្ថុស្មោកគ្រោក ។





ដើម្បីរក្សាការស្អាតត្រូវធ្វើដូចម្ដេច ?

១) ងូតទឹកកុំខាន ។

២) ដុសធ្មេញពេលព្រឹកនិងពេលល្ងាច ។

៣) សិតសក់ជានិច្ច ។

៤) កាត់ក្រចកកុំខាននិងខិតខំឲ្យវាស្អាត ។



៥) យកចិត្តទុកដាក់នឹងសំលៀកបំពាក់ ត្រូវឲ្យវាស្អាតនិងអ៊ុតវាជានិច្ច ។



លើសពីស្អាត អ្នកត្រូវយកចិត្តទុកដាក់អំពីការបរិភោគ ។ អ្វីដែលអ្នកបរិភោគនោះត្រូវស្អាត (និងហាឡាល់) ។ ត្រូវលាងផ្លែឈើមុនយកវាមកបរិភោគ ។

អ្នកត្រូវយកចិត្តទុកដាក់អំពីវត្ថុដែលនៅជុំវិញខ្លួនអ្នក ចូរឲ្យវត្ថុទាំងនោះស្អាត គឺៈ ផ្ទះអ្នក បន្ទប់ដេករបស់អ្នក, ទូដាក់អីវ៉ាន់របស់អ្នក ។ល ។





# លំហាត់ ៩

ចូរសរសេរនៅក្នុងរង្វង់មូលឯទៀតរបស់ដែលអ្នកត្រូវសម្អាត ។

ឧទាហរណ៍

បោកខោអាវ

## មេរៀនទី ១០

# គោរពឪពុកម្តាយ

អល់ឡោះហ្ជ មានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ អាយ៉ាស់ ៨៣ ថា៖ *"ចូរពួកអ្នកគោរពបូជាតែអល់ឡោះហ្មួយ ចូរពួកអ្នកប្រព្រឹត្តល្អចំពោះឪពុកម្តាយទាំងពីរ..."(២:៨៣)*

ដែលអល់ឡោះហ្ជ ថានៅក្នុងឃ្លាតែមួយ ឲ្យធ្វើល្អចំពោះឪពុកម្តាយយើងផ្ទឹមនឹងឲ្យធ្វើប្រការសំខាន់បំផុត ពោលគឺឲ្យយើងគោរពសក្ការតែព្រះអង្គជ មួយគត់នោះ សឲ្យឃើញថាគោរពឪពុកម្តាយយើងជាប្រការសំខាន់ណាស់ក្នុងសាសនាអ៊ីស្លាម ។

ព្រះសាស្តា ﷺ មានព្រះវចនៈថា ផ្គាប់ចិត្តអល់ឡោះហ្ជ នៅក្នុងការផ្គាប់ចិត្តឪពុកម្តាយ ។ ព្រះពិរោធអល់ឡោះហ្ជ នៅក្នុងកំហឹងឪពុកម្តាយ ។

នេះបញ្ជាក់ឲ្យដឹងថាពេលយើងធ្វើឲ្យឪពុកម្តាយសប្បាយចិត្ត យើងធ្វើឲ្យអល់ឡោះហ្ជ ទ្រង់សព្វព្រះទ័យដែរ ពេលយើងធ្វើឲ្យឪពុកម្តាយក្រោធ យើងធ្វើឲ្យអល់ឡោះហ្ជ ទ្រង់ព្រះពិរោធដែរ ។

ធ្វើល្អចំពោះឪពុលម្តាយ ធ្វើឲ្យឪពុកម្តាយសប្បាយចិត្ត មិនធ្វើឲ្យឪពុកម្តាយក្រោធទេ ស្មើនឹងគោរពឪពុកម្តាយ ។

ឪពុកម្តាយអ្នកបានលះបង់សព្វគ្រប់ដើម្បីអ្នក ។ ដោយសារឪពុកម្តាយអ្នកបានជាអ្នករស់រានមានជីវិតនៅក្នុងលោកសព្វថ្ងៃនេះ ។

ម្តាយអ្នកបានពអ្នកក្នុងពោះ ៩ ខែ ហើយបានសម្រាលអ្នក បានចិញ្ចឹមអ្នកមើលថែរក្សាអ្នកមិនឲ្យខ្វះអ្វីមួយឡើយ ។

អាស្រ័យហេតុនេះឯងបានជា ក្នុងសាសនាអ៊ីស្លាម យើងថាឋានសួគ៌នៅក្រោមបាតជើងម្តាយអ្នក ។

ឪពុកម្តាយអ្នកនៅជាប់នឹងអ្នកជានិច្ច ។ ពេលអ្នកឈឺ លោកមើលថែរក្សាអ្នក ។ ពេលអ្នកស្រពោនចិត្ត លោកក៏ស្រពោនចិត្តដែរ ។ ពេលអ្នកត្រូវការជំនួយ

អ្នកអាចពឹងពាក់លោកបានជានិច្ច ។

លោកបួងសួងឲ្យអ្នកដោយមិនបាច់ឲ្យអ្នកសូម ឬដោយមិនឲ្យអ្នកដឹង ។

អ្នកមិនអាចសងអ្វីដែលលោកបានធ្វើដើម្បីអ្នកនោះបានទេ តែអ្នកអាចអរគុណលោកដោយគោរពលោក ។

គោរពឪពុកម្ដាយអ្នកបានសេចក្ដីថាអ្វី ?

គោរពឪពុកម្ដាយអ្នកគឺ៖

១) ធ្វើល្អជានិច្ចចំពោះលោក ។

២) ធ្វើឲ្យលោកសប្បាយចិត្តជានិច្ច ។

៣) កុំធ្វើឲ្យលោកអន់ចិត្តឬក្រោធឡើយ ។

៤) ធ្វើការនីមួយឲ្យលោកដោយមិនបាច់ឲ្យគាត់សូមអ្នក ។

៥) កុំគំហកដាក់លោកឡើយ ។

៦) កុំប្រជែងនិយាយជាមួយលោកឡើយ ។

៧) កុំដើរពីមុខលោក លើកលែងតែលោកអនុញ្ញាត ។

៨) កុំអង្គុយពេលលោកឈរ ។ បើអ្នកកំពុងអង្គុយពេលលោកចូលមកក្នុងបន្ទប់ អ្នកត្រូវងើបឈរលុះត្រាតែលោកអង្គុយ ។

៩) ឲ្យសាឡាមលោកនិងឱបថើបលោកជានិច្ច ។ នេះគឺប្រការដំបូងបង្អស់ដែលត្រូវធ្វើពេលព្រឹក ពេលអ្នកត្រឡប់មកពីណាវិញឬពេលលោកត្រឡប់មកពីខាងក្រៅផ្ទះវិញ ។

១០) ត្រូវអរគុណលោកនិងបួងសួងអល់ឡោះហ៍ﷻឲ្យលោកជានិច្ច ។

អាយ៉ាស់ខាងក្រោមនេះដកស្រង់ពីក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ បានី-អ៊ីសរ៉អ៊ីល អាយ៉ាស់ ២៤ គឺ៖

رَّبِّ ٱرْحَمْهُمَا كَمَا رَبَّيَانِى صَغِيرًا

*"ព្រះម្ចាស់អើយ សូមព្រះអង្គមានព្រះមេត្តាធម៌ដល់លោកទាំងពីរ ឲ្យដូចកាលដែលលោកទាំងពីរបានចិញ្ចឹមទូលព្រះបង្គំជាខ្ញុំកាលពីតូចផង ។" (១៧:២៤)*

អ្នកត្រូវសូត្រឌូអាអ៊ ខ្លីនេះឲ្យបានញឹកញយ តាមដែលអាចធ្វើបានក្នុងមួយថ្ងៃ

ជាពិសេសរាល់ពេលស្វ័ឡាត់ ។

## លំហាត់ ១០

ចូរទន្ទេញឌូអាអ៍ខាងក្រោមនេះ ហើយសរសេរពាក្យសម្រាយវា គឺ៖




ចូរសរសេរសំបុត្រខាងក្រោមនេះជូនចំពោះឪពុកម្ដាយអ្នកគឺ៖

ជូនចំពោះលោកឪពុក អ្នកម្ដាយជាទីស្រឡាញ់ ។
កូនសូមអរគុណ លោកឪពុក អ្នកម្ដាយដែលបាន ៖

កូនស្រឡាញ់លោកឪពុក អ្នកម្ដាយណាស់ ។
ហត្ថលេខា ៖

**មេរៀនទី ១១**

# គោរពគ្រូ

គ្រូដែលបង្រៀនអ្វីក៏ដោយ នៅឯសាលារៀនឬនៅឯម៉ាដ្រ៉សាស្ស៍ (مَدْرَسَة គឺសាលាបង្រៀនសាសនាអ៊ីស្លាម) ធ្វើតាមគំរូព្រះសាស្តា ﷺ និងអ៊ីមុាំ عليهم السلام ដែលជាគ្រូដែរព្រោះព្រះអង្គ عليهم السلام បង្រៀនយើងឲ្យស្គាល់ផ្លូវល្អ ។

ដូចឪពុកម្តាយអ្នកដែរដែលអ្នកត្រូវគោរពនោះ ព្រោះលោកមានគុណដល់អ្នក អ្នកក៏ត្រូវគោរពលោកគ្រូអ្នកគ្រូដែរដែលបង្ហាត់អ្នកឲ្យចេះដឹង អាស្រ័យចំណេះចេះដឹងទាំងនេះ អ្នកនឹងមានអនាគតភ្លឺថ្លា ។

អ្នកអាចទទួលបាននូវចំណេះវិជ្ជាលុះណាតែអ្នក ៖

-ស្តាប់លោកគ្រូអ្នកគ្រូ ។

-យកចិត្តទុកដាក់ ។ ចូរអ្នកខិតខំសិក្សាឲ្យយល់អ្វីដែលគ្រូប្រាប់អ្នក ។

តើគោរពលោកគ្រូអ្នកគ្រូដូចម្តេច ?

១) អ្នកត្រូវក្រោកឈរហើយឲ្យសាឡាមពេលគ្រូចូលមកក្នុងបន្ទប់រៀន ។



២) អ្នកមិនត្រូវនិយាយគ្នាទេពេលគ្រូនិយាយ ។

៣) អ្នកមិនត្រូវកាត់ប្រសាសន៍គ្រូទេ ។

៤) បើអ្នកចង់និយាយ អ្នកត្រូវលើកដៃហើយចាំឲ្យគ្រូសួរអ្នក ។



៥) អ្នកមិនត្រូវឆ្លើយជំនួសទេពេលគ្រូសួរអ្នកផ្សេង ។

៦) អ្នកត្រូវអង្គុយឲ្យត្រឹមត្រូវនៅលើកៅអី ។



៧) អ្នកត្រូវមើលមកគ្រូជានិច្ច ។

៨) អ្នកមិនត្រូវបរិភោគឬផឹកទេនៅក្នុងបន្ទប់រៀន ។

៩) អ្នកមិនត្រូវគូសឬសរសេរអ្វីទេពេលគ្រូនិយាយ ។

១០) អ្នកត្រូវអរគុណាគ្រូដែលលះបង់ពេលវេលា ដើម្បី
បង្ហាត់បង្រៀនអ្នក ។



## លំហាត់ ១១

ចូរសរសេរលើសញ្ញា "ផ្កាភ្លើង" ថាអ្នកគោរពគ្រូបែបណា ។ ហើយសូមឲ្យគ្រូគូសប្រការដែលអ្នកបានធ្វើហើយ ។ បើគ្រូគូសទាំងអស់ ចូរសរសេរឈ្មោះអ្នកនៅលើពានមាស ។



## មេរៀនទី ១២

# ធ្វើឲ្យគេតូចចិត្ត

អារម្មណ៍គឺចិត្តរបស់អ្នក សប្បាយឬសោកសៅ ។



ពេលអ្នកធ្វើឲ្យអ្នកដទៃឈឺខ្លួន គេអាចព្យាបាលបានដោយថ្នាំហើយជាវិញបាន ។ តែបើអ្នកធ្វើឲ្យអ្នកដទៃឈឺចិត្ត អ្នកធ្វើឲ្យគេតូចចិត្ត មិនមានថ្នាំព្យាបាលទេ ។ របួសនោះជ្រៅជាង ឈឺយូរជាង ។ អាចដល់ថ្នាក់ធ្វើឲ្យអ្នករងរបួសចិត្តនោះដូរចិត្តគំនិតអំពីខ្លួនឯងបាន (លែងទុកចិត្តខ្លួនឯងជាដើម) ។

ពេលអ្នកចំអកដាក់គេ ៖

-ចូរអ្នកគិតមើលថាតើអ្នកមានអារម្មណ៍យ៉ាងណា បើអ្នកដែលត្រូវគេចំអកឲ្យនោះជាខ្លួនអ្នក ។

-ចូរអ្នកគិតមើលថាតើអ្នកធ្វើឲ្យគេឈឺប៉ុណ្ណា ។

-ចូរអ្នកប្រាប់ខ្លួនឯងថាអ្នកនោះអាចលែងទុកចិត្តខ្លួនឯង (វាអាចជះឥទ្ធិពលអាក្រក់មកលើខ្លួនអ្នកនោះក្នុងជីវិតរស់នៅ) ។

ដូច្នេះ អំណឹះតទៅ ពេលអ្នកសើចចំអកឲ្យគេ ចូរគិតដល់ ៣ ប្រការនេះ ។

ចូរចងចាំថា អ្នកនឹងត្រូវសាកសួរអំពីរាល់ទង្វើរបស់អ្នកក្នុងថ្ងៃជំនុំជម្រះ ។ អល់ឡោះហ្វ៍عز وجلមានព្រះបន្ទូលថា ព្រះអង្គعز وجلអាចលើកទោសឲ្យអ្នកបានដែលអ្នកបានធ្វើខុសមកលើព្រះអង្គعز وجل (ដែលមិនបានស្វ៊ឡាត់ ឬ មិនបានកាន់សីលត្រណមឧទាហរណ៍) តែព្រះអង្គعز وجلនឹងមិនលើកទោសឲ្យអ្នកទេដែលអ្នកបានធ្វើខុសចំពោះអ្នកដទៃនោះ (ដោយបានធ្វើឲ្យគេតូចចិត្ត) ។

ដូច្នេះ ចូរអ្នកសូមទោសអ្នកណាមួយដែលអ្នកបានធ្វើឲ្យអាក់អន់ស្រពន់ចិត្ត ហើយចូរកុំធ្វើឲ្យអ្នកដទៃតូចចិត្តអំណឹះតទៅទៀតឡើយ ។

# លំហាត់ ១២

ចូរអ្នកគូររូបអ្នកនៅលើផ្ទៃបួនជ្រុង ហើយសរសេរនៅលើសំណុំទាំងអស់ ៣ ប្រការដែលអ្នកត្រូវគិតដល់ ។



## មេរៀនទី ១៣

# បាបតូចនិងបាបធំ

អ៊ីម៉ាំទី ១ របស់យើង អ៊ីម៉ាំអាលី صلوات الله عليه والسلام មានវចនៈថាបាបធំជាងគេដែលបុគ្គលប្រព្រឹត្តនោះគឺបាបដែលខ្លួនគិតថាជាបាបតូចតាច ។

ពេលអ្នកធ្វើអ្វីមួយដែលអ្នកឃើញថាវាជាទង្វើអាក្រក់ អ្នកនឹងមានអារម្មណ៍ថាមានទោស អ្នកនឹងសូមខមាទោសអល់ឡោះហ៊្ជ عز وجل ហើយអ្នកនឹងព្យាយាមមិនធ្វើអំពើអាក្រក់នោះម្តងទៀតទេ ។

តែបើពេលអ្នកធ្វើអ្វីមួយដែលអ្នកមិនគិតថាវាជាអំពើអាក្រក់ទេ ទោះបីវាជាបាបក៏ដោយ អ្នកមិននឹកស្តាយទេហើយអ្នកបំភ្លេចវាចោល ។ ដូច្នេះឯងដែលបាបតូចៗទាំងនោះនឹងមូលផ្តុំគ្នាធំឡើងៗទាល់តែគរដូចភ្នំបាប (អាចប្រៀបបាននឹងកាក់ប្រាក់ដែលអ្នកដាក់សន្សំក្នុងហឹបសន្សំប្រាក់ វាកើនឡើងបន្តិចម្តងៗទាល់តែបានច្រើន) ។

ថ្ងៃមួយ សម័យអ៊ីម៉ាំទី ៦ របស់យើង គឺអ៊ីម៉ាំ យ៉ាក់ហ្វារ អាស្វ-ស្វ៊ឌិក្ក صلوات الله عليه والسلام មានបុរសពីរនាក់មករកព្រះអង្គ صلوات الله عليه والسلام ហើយថាពួកគាត់ចង់សូមខមាទោសអល់ឡោះហ៊្ជ عز وجل ដែលបានធ្វើអំពើបាបកាលពីមុន ។

បុរសមួយបានថាគាត់បានធ្វើអំពើបាបធំពីរ បុរសមួយទៀតបានថាគាត់បានធ្វើតែអំពើបាបតូចៗច្រើនទេ ។

អ៊ីម៉ាំ صلوات الله عليه والسلام បានប្រាប់បុរសទាំងពីរឲ្យយកដុំថ្មមកឲ្យព្រះអង្គ صلوات الله عليه والسلام ថ្មមួយដុំសម្រាប់បាបមួយ ។ តែបុរសដែលបានប្រព្រឹត្តបាបធំនោះត្រូវយកថ្មពីរដុំធំៗ ចំណែកឯបុរសម្នាក់ទៀតត្រូវយកមកនូវដុំក្រួស ។

ក្រោយមកបន្តិច បុរសទាំងពីរត្រឡប់មករកអ៊ីម៉ាំ صلوات الله عليه والسلام វិញ ។ បុរសដែលបានប្រព្រឹត្តបាបធំនឿយហត់ដោយសារលីដុំថ្មធំៗដែលធ្ងន់ រីឯបុរសម្នាក់ទៀតមិននឿយហត់ទេ ។

អ៊ីម៉ាំ صلوات الله عليه والسلام បានឲ្យបុរសទាំងពីរយកថ្មទៅដាក់កន្លែងដើមរបស់វា ដែលបានយក

វាមក ឲ្យចំកន្លែងវាវិញ មិនឲ្យខុសបន្តិចឡើយ ។

បុរសដែលបានប្រព្រឹត្តបាបធំ ឃើញថានឿយហត់និងពិបាកខ្លាំងណាស់ តែគាត់អាចយកដុំថ្មទៅដាក់កន្លែងដើមបានវិញ ។

បុរសដែលបានប្រព្រឹត្តបាបតូចៗបានរើសដុំគ្រួសច្រើនណាស់ មកពីគ្រប់ទីកន្លែង គាត់មិនចាំកន្លែងដើមរបស់គ្រួសទាំងនោះទេ មិនអាចយកគ្រួសទៅដាក់កន្លែងដើមវិញបានទេ ។

ឧត្តមគតិរឿងនេះគឺ ពិបាកសូមខមាទោសអល់ឡោះហ្ជ័ សម្រាប់បាបដែលយើងចាត់ទុកថាជាបាបតូច (ឬស្រាល) នោះ ព្រោះយើងភ្លេចវា ។ យើងត្រូវទុកបាបនីមួយជាប្រការដែលអល់ឡោះហ្ជ័ ស្អប់ មិនត្រូវមើលស្រាលបាបនោះទេ ។

## លំហាត់ ១៣

ចូរគូសមុខព្រួញទៅរកទិសដៅដែលដៃជញ្ជីងនឹងបាស់ទៅរក ។ ហេតុអ្វី ។




ចូរយកក្រដាសមួយសន្លឹកមកកាត់ជាពីរ ។ យកមួយកំណាត់សន្លឹកមកកាត់ជាពីរ យកមួយកំណាត់ទៀតមកកាត់ជាច្រើនកំណាត់តូចៗ ។ ចូរគិតថាមួយកំណាត់ៗជាបាបមួយ កំណាត់ធំជាបាបធំ កំណាត់តូចជាបាបតូច ។ បន្ទាប់មកចូរពន្រាយកំណាត់ក្រដាសទាំងអស់នៅលើតុ រួចហើយយកកំណាត់ទាំងនោះទៅដាក់កន្លែងដើមវិញដើម្បីឲ្យមានសណ្ឋានជាសន្លឹកក្រដាសដើមវិញ ។

តើងាយរៀបកំណាត់តូចៗឬកំណាត់ធំៗ ? ហេតុអ្វី ?

**មេរៀនទី ១៤**

# របៀបចូលក្នុងផ្ទះ

ពេលអ្នកចូលក្នុងផ្ទះ ត្រូវឈានជើងស្តាំចូលមុន ។

ពេលចូល ចូរសូត្រឌូអាអ៊ំនេះ គឺ៖

بِسْمِ اللهِ الرَّحْمٰنِ الرَّحِيمِ

*ដោយនូវព្រះនាមអល់ឡោះហ្ព៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

اللّٰهُمَّ إِنِّي أَسْأَلُكَ خَيْرَ الْمَوْلِجِ وَخَيْرَ الْمَخْرَجِ بِسْمِ اللّٰهِ وَلَجْنَا وَبِسْمِ اللّٰهِ خَرَجْنَا وَعَلَى اللّٰهِ رَبِّنَا تَوَكَّلْنَا

*អល់ឡោះហ្ព៍ﷻអើយ សូមព្រះអង្គﷻប្រទានឲ្យទូលព្រះបង្គំជាខ្ញុំកន្លែងចូលដែលល្អ និងកន្លែងចេញដែលល្អ ។ ក្នុងព្រះនាមអល់ឡោះហ្ព៍ﷻ អស់ទូលព្រះបង្គំជាខ្ញុំចូល ក្នុងព្រះនាមអល់ឡោះហ្ព៍ﷻ អស់ទូលព្រះបង្គំជាខ្ញុំចេញ ។ អស់ទូលព្រះបង្គំជាខ្ញុំអាស្រ័យអល់ឡោះហ្ព៍ﷻ ព្រះអភិបាលរបស់អស់ទូលព្រះបង្គំជាខ្ញុំ ។*

ពេលអ្នកបានចូលក្នុងផ្ទះហើយ អ្នកត្រូវទៅរកឪពុកម្តាយ ថើបលោកហើយថា៖ اَلسَّلَامُ عَلَيْكُمْ

# លំហាត់ ១៤

គាត់មិនចាំថាត្រូវចូលក្នុងផ្ទះដោយឈានជើងណាមុនទេ ។ ចូរជួយប្រាប់គាត់ ។



ចូរទន្ទេញឌូអារ៉ នេះដែលអ្នកត្រូវសូត្រពេលចូលក្នុងផ្ទះ គឺ៖

بِسْمِ اللهِ الرَّحْمٰنِ الرَّحِيمِ
اللَّهُمَّ إِنِّي أَسْأَلُكَ خَيْرَ الْمَوْلِجِ وَخَيْرَ الْمَخْرَجِ بِسْمِ اللَّهِ وَلَجْنَا
وَبِسْمِ اللَّهِ خَرَجْنَا وَعَلَى اللَّهِ رَبِّنَا تَوَكَّلْنَا



**មេរៀនទី ១៥**

# របៀបចេញពីផ្ទះ

មុនចេញពីផ្ទះ ចូរឆ្លុះកញ្ចក់ ។ តើអ្នកស្លៀកពាក់ស្របតាមរបៀបក្មេងប្រុសឬក្មេងស្រីមុស្លីមស្លៀកពាក់ទេ ? បើអ៊ីមុាំ ១២ របស់យើងងើបឡើងតើព្រះអង្គ صلوات الله عليه والسلام យល់ស្របនឹងសំលៀកបំពាក់អ្នកទេ ?

ចូរអ្នកសូមអនុញ្ញាតពីឪពុកម្តាយសិនមុននឹងទៅណា ឲ្យលោកដឹងថាកន្លែងនោះល្អឬទេ ។

បន្ទាប់ពីនោះអ្នកត្រូវថា ហ្វី អាម៉ានីលឡាស់ (فِي أَمَانِ اَللَّهِ) ឬ ឃូដ្វា ហ្វាហ្វ៊ីស្ព (خُدَا حَافِظ) ឲ្យអ្នកផ្ទះទាំងអស់គ្នា ។ ចូរកុំភ្លេចឱបថើបឪពុកម្តាយ ។

មុនចេញពីផ្ទះ ចូរអ្នកសូត្រឌូអាអ៊ុំខ្លីនេះ គឺៈ

بِسْمِ اَللَّهِ اَلرَّحْمٰنِ اَلرَّحِيمِ

*ដោយនូវព្រះនាមអល់ឡោះហ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

بِسْمِ اللَّهِ تَوَكَّلْتُ عَلَى اللَّهِ لَا حَوْلَ وَلاَ قُوَّةَ إِلَّا بِاللَّهِ.

*ក្នុងព្រះនាមអល់ឡោះហ៍ عزّ وجلّ ទូលព្រះបង្គំជាខ្ញុំអាស្រ័យអល់ឡោះហ៍ عزّ وجلّ ។ ឥទ្ធិពលនិងអំណាចកើតមានឡើងបានអាស្រ័យតែអល់ឡោះហ៍ عزّ وجلّ ។*

នៅក្នុងឌូអាអ៊ុំនេះ អ្នកថាអល់ឡោះហ៍ عزّ وجلّ ខ្លាំងពូកែជាច់គេ ថាអ្នកសូមឲ្យព្រះអង្គ عزّ وجلّ ការពារអ្នក ។

យកល្អអាចសូត្រស៊ូរ៉ោះត៍ អាល់-អ៊ិះខ៍ឡាស្វ ៣ ចប់បានដែរពេលចេញពីផ្ទះ ។

ពេលចេញអ្នកត្រូវឈានជើងស្តាំមុន ។

## លំហាត់ ១៥

ចូរគូរសំលៀកបំពាក់ដែលអ្នកអាចពាក់ សម្រាប់ចេញទៅក្រៅផ្ទះជាមួយមិត្តអ្នក បើអ្នកជាគ្ម៏លិបឬគ្ម៏លីបាស្ញ ។





ចូរសូត្រឌូអាអ៊ំនេះពេលចេញពីផ្ទះ គឺ៖

بِسْمِ اَللهِ اَلرَّحْمٰنِ اَلرَّحِيمِ

بِسْمِ اللَّهِ تَوَكَّلْتُ عَلَى اللَّهِ لَا حَوْلَ وَلاَ قُوَّةَ إِلَّا بِاللَّهِ.



## មេរៀនទី ១៦

# កំហឹង

អល់ឡោះហ្ទ៍ﷻមានព្រះបន្ទូលនៅក្នុងព្រះមហាគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាលី អ៊ីមរ៉ន ថា៖ *"[មនុស្សល្អគឺ]បណ្តាអ្នកដែលទប់កំហឹងនិងអត់ឱនឲ្យបណ្តាមនុស្ស ។ អល់ឡោះហ្ទ៍សព្វព្រះហឫទ័យបណ្តាអ្នកប្រព្រឹត្តល្អ ។" (៣:១៣៤)*

អាយ៉ាស់នេះប្រដៅយើងឲ្យចេះ "ទប់" កំហឹង (កាស្ទីម អាល់-ក្ហយ់ស៍ كظم الغيظ) នេះជាឈ្មោះមួយរបស់អ៊ីម៉ាំទី ៧ របស់យើង ព្រោះព្រះអង្គصلوات الله عليه والسلامទប់កំហឹងជាញឹកញយ ។

ហេតុអ្វីការទប់កំហឹងជាប្រការសំខាន់ខ្លាំង ?

សាសនាអ៊ីស្លាមចែងថា លក្ខណៈដែលបញ្ជាក់ថាមនុស្សប្រសើរជាងសត្វនោះគឺប្រាជ្ញាយើង សមត្ថភាពចេះរិះគិតរបស់យើងដោយប្រើប្រាជ្ញាយើង ។

ពេលអ្នកក្រោធ អ្នកបាត់បង់សមត្ថភាពចេះគិតនិងចេះវិនិច្ឆ័យនេះ ។ ដូច្នេះឯងបានជាមនុស្សភាគច្រើនថាពាក្យ ឬធ្វើទង្វើនីមួយក្រោមឥទ្ធិពលកំហឹងហើយក៏ស្តាយក្រោយវិញ ចង់ដកឬលុបបំបាត់ពាក្យឬទង្វើនោះចោលវិញពេលបាត់ក្រោធ ។

ពិបាកបកក្រោយវិញណាស់ ដូច្នេះហើយបានជាយើងត្រូវគិតមុនថាឬធ្វើអ្វីមួយ ។ ដើម្បីរក្សាសមត្ថភាពចេះគិតនេះអ្នកត្រូវចេះគ្រប់គ្រងកំហឹងអ្នក ។

តើទប់កំហឹងដូចម្តេចទៅ ?

អ៊ីម៉ាំអាលីصلوات الله عليه والسلامមានវចនៈថាពេលអ្នកកំពុងឈរ ហើយកើតមានកំហឹងឡើង អ្នកត្រូវអង្គុយចុះ ។ បើអ្នកកំពុងអង្គុយហើយក៏កើតមានកំហឹងឡើង អ្នកត្រូវដេក ។

ធ្វើដូច្នេះដើម្បីនឹងឲ្យអ្នកមានពេលគិត នឹងអាចគ្រប់គ្រងកំហឹងអ្នកបាន ។

ព្រះសាស្តាﷺយើងមានព្រះវចនៈថា កំហឹងចេញមកពីស្ហៃតូនلعنه اللهដែលត្រូវបង្កើតពីភ្លើង ។ គេពន្លត់ភ្លើងដោយទឹក ដូច្នេះហើយបានជារាល់ពេលដែលអ្នកមាន

អារម្មណ៍ថាក្រោធ អ្នកត្រូវយកទឹកវូឌុអ៍ ។

តែមិនបានសេចក្ដីថាអ្នកមិនត្រូវក្រោធសោះឡើយនោះទេ ពីព្រោះកំហឹងជាអារម្មណ៍មួយ បើអ្នកចេះប្រើអារម្មណ៍នេះដោយត្រឹមត្រូវ វាអាចធ្វើឲ្យចិត្តអ្នករឹងប៉ឹងបាន ។

បើអ្នកណាមួយធ្វើអាក្រក់ដោយចេតនា ដូចជាវាយប្រហារបៀតបៀនគេ ប្រមាថអល់ឡោះហ៍ﷻ ប្រមាថព្រះសាស្ដាﷺ ប្រមាថអ៊ីមុាំعليهم السلام ជាដើម អ្នកត្រូវក្រោធតែត្រូវប្រើប្រាជ្ញានិងគំនិតដែរ ។

## លំហាត់ ១៦

តើខុសគ្នាត្រង់ណាវាងយើងនិងសត្វគោនេះឬសត្វផ្សេងឯទៀត ?



ចូរផាត់ពណ៌រូបគោ ហើយសរសេរពីក្រោមគ្រប់ប្រការដែលអ្នកត្រូវធ្វើអំណឺះត ទៅពេលអ្នកក្រោធ ។

**មេរៀនទី ១៧**

# អ៊ីសរ៉ហ្វ (إِسْراف ការខ្ជះខ្ជាយ)

អល់ឡោះហ្ទ៍ﷻមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាល់-អាក់រ៉ហ្វ អាយ៉ាស់ ៣១ ថា៖ *"ម្នាលកូនចៅអាដាំអើយ ចូរពួកអ្នកស្លៀកពាក់ល្អនាគ្រប់ទីកន្លែងធ្វើនមស្ការ ។ ចូរពួកអ្នកបរិភោគនិងផឹក ចូរកុំប្រព្រឹត្តហួសហេតុព្រោះអល់ឡោះហ្ទ៍មិនសព្វព្រះហឫទ័យអ្នកប្រព្រឹត្តិហួសហេតុទេ ។" (៧:៣១)*

អាយ៉ាស់នេះបញ្ជាក់ប្រាប់យើងថាគេអនុញ្ញាតឲ្យមានរបស់ល្អៗ តែមិនឲ្យសម្បូរហួសហេតុដល់ថ្នាក់ខ្ជះខ្ជាយទេ ។

អ៊ីមុាំអាលីصلوات الله عليه والسلامមានវចនៈថា៖ "ចូរប្រកបកិច្ចការសម្រាប់លោកនេះដូចជាលោករស់នៅក្នុងលោកនេះរហូត ចូរប្រកបកិច្ចការសម្រាប់លោកមុខដូចជាលោកត្រូវស្លាប់ថ្ងៃស្អែក ។"

មានន័យថាយើងត្រូវធ្វើការក្នុងលោកនេះ ដើម្បីនឹងមានជីវិតរស់នៅស្រណុក តែដោយមិនធ្វើឲ្យអ្នកដទៃខូចខាតទេ ។

បើអល់ឡោះហ្ទ៍ﷻអាណិតអាសូរយើងដោយប្រទានឲ្យយើងនូវអ្វីមួយ (ទ្រព្យសម្បត្តិជាដើម) យើងអាចប្រើប្រាស់ចាយវាយបាន តែយើងត្រូវគិតដល់អ្នកដទៃផងដែលមិនសម្បូរដូចយើងទេនោះ យើងត្រូវជួយគេផង ។

អល់ឡោះហ្ទ៍ﷻមិនសព្វព្រះទ័យទេ ដែលអ្នកទិញរបស់ណាដែលអ្នកមិនត្រូវការឬដែលអ្នកមិនប្រើ ។

អល់ឡោះហ្ទ៍ﷻមិនសព្វព្រះទ័យទេ ដែលអ្នកគិតថាគ្រាន់បើជាងម្នាក់ទៀតព្រោះតែអ្នកមានជាងអ្នកនោះ ព្រោះអល់ឡោះហ្ទ៍ﷻជាអ្នកឲ្យនិងជាអ្នកយក ។

អ្នកមិនត្រូវទិញរបស់ណា ដែលធ្វើឲ្យអ្នកមានទំនងដូចជាប្រសើរជាងអ្នកដទៃ ឬដែលធ្វើឲ្យអ្នកដទៃគិតថាខ្លួនដូចជាមានតម្លៃអន់ជាងគេនោះទេ ។

អ្នកត្រូវប្រយ័តខ្លួន ចូរកុំឲ្យខ្ជះខ្ជាយសំលៀកបំពាក់ ចូរកុំឲ្យខ្ជះខ្ជាយរបស់លេង ចូរកុំឲ្យខ្ជះខ្ជាយសៀវភៅអាន ចូរកុំឲ្យខ្ជះខ្ជាយគ្រឿងបរិភោគ ។

ត៏លិបហូបបាយមិនអស់ ។ ម្ដាយវាថាវាខ្ជះខ្ជាយ ។

ត៏លិបមិនយល់ទេថាតើវាធ្វើអ្វីខុស វាគ្រាន់តែដួសបាយលើសពីហូបអស់ប៉ុណ្ណោះព្រោះវាឃើញមានម្ហូបដែលវាចូលចិត្ត តែពេលនេះវាហូបមិនអស់ ។

ម្ដាយត៏លិបពន្យល់វាថាវាមិនគិតដល់អ្នកដទៃក្រៅពីខ្លួនវាទេ ។ ពេលឃើញម្ហូបដែលវាចូលចិត្ត វាដួសយកយ៉ាងច្រើនខ្លាចគេហូបអស់មិនទុកឲ្យវា ។

វាគួរតែដួសយកបន្តិចមកហូប ហូបអស់ហើយដួសយកបន្តិចទៀត ដើម្បីនឹងកុំឲ្យសល់យកទៅចោលព្រោះតែវាលែងឃ្លាន ។

អ្នកត្រូវគិតដល់អ្នកដទៃដែលមិនសម្បូរដូចអ្នក មិនត្រូវខ្ជះខ្ជាយអ្វីដែលអល់ឡោះហ៍ عز وجل ប្រទានឲ្យអ្នកទេ តែអ្នកគប្បីប្រើរបស់នោះជាមួយអ្នកដទៃ បែងចែករបស់នោះឲ្យអ្នកដទៃ ។

# លំហាត់ ១៧

តើក្មេងលិបធ្វើអ្វីខុស ? តើវាគប្បីធ្វើដូចម្ដេច ?



តើគេខ្ជះខ្ជាយចំពោះតែគ្រឿងបរិភោគទេ ?
តើអ្នកត្រូវប្រយ័តអំពីអ្វីទៀតដើម្បីចៀសវាងការខ្ជះខ្ជាយ ?

*Sources:*
*imamia.org*
*shia974.fr*
*madressa.net*
*page-borders.com*
*openclipart.org*